# របាយការណ៍
# វឌ្ឍនភាពនៃការធ្វើសកម្មភាពរបស់សមាគម
# និងអង្គការមិនមែនរដ្ឋាភិបាល បន្ទាប់ពីវេទិកាលើកទី៣
# ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល
# ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
# រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា**
- **ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្ត**
- **ឯកឧត្តម លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍នានា**
- **លោក លោកស្រីជាមន្ត្រីរាជការ អស់លោក លោកស្រីតំណាងអង្គការសង្គមស៊ីវិល សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល ជាទីមេត្រី!**

ខ្ញុំសូមអនុញ្ញាតធ្វើសេចក្តីរាយការណ៍អំពីវឌ្ឍនភាពនៃកិច្ចសហការជាមួយ អង្គការសង្គមស៊ីវិល បន្ទាប់ពីវេទិកាលើកទី៣ រហូតដល់វេទិកាលើកទី៤ ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលមានខ្លឹមសារដូចតទៅៈ

-វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៣ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។ ដោយឡែក ក្នុងឆ្នាំ២០១៩ រដ្ឋបាលរាជធានីខេត្តទាំងអស់ បានរៀបចំវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានចំនួន២(ពីរ)លើក ដើម្បីធ្វើការដោះស្រាយនូវសំណើ សំណូមពរ និងកង្វល់របស់អង្គការសង្គមស៊ីវិល។

-ផ្អែកលើមូលដ្ឋានខាងលើ ក្រសួងមហាផ្ទៃពិនិត្យឃើញថា ជារួមការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិលនៅតាមមូលដ្ឋាន មានភាពល្អប្រសើរជាធម្មតា ដោយមិនមានការរឹតត្បិតក្នុងការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិលជាដុំកំភួនឡើយ។ ជាក់ស្តែង ក្នុងអំឡុងឆមាសទី២ ឆ្នាំ២០១៩កន្លងមកនេះ ក្រសួងមហាផ្ទៃ តាមរយៈយន្តការក្រុមការងារអន្តរក្រសួងដើម្បីដោះស្រាយសំណើ សំណូមពររបស់អង្គការសង្គមស៊ីវិល បានទទួលនូវសេចក្តីរាយការណ៍ចំនួនតែ២(ពីរ)ករណីប៉ុណ្ណោះ គឺនៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងការរារាំងសកម្មភាពរបស់

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ចំពោះករណីនេះ ក្រុមការងារអន្តរក្រសួងក៏បានធ្វើការទំនាក់ទំនងដោយផ្ទាល់ទៅរដ្ឋបាលខេត្តទាំងពីរ ដើម្បីជួយសម្របសម្រួល និងដោះស្រាយបញ្ហាដែលបានកើតឡើងនោះបានរួចរាល់ផងដែរ។

-លើសពីនេះទៀត ដើម្បីជួយសម្រួលដល់អង្គការសង្គមស៊ីវិលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានចេញសេចក្តីជូនដំណឹងពន្យារពេលក្នុងការចុះបញ្ជីពន្ធដារ និងការបំពេញកាតព្វកិច្ចសារពើពន្ធដោយពុំមានការពិន័យរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតធ្វើសេចក្តីរាយការណ៍ដោយសង្ខេបអំពីលទ្ធផលនៃអង្គវេទិកាលើកទី៣ និងដំណើរការពិគ្រោះយោបល់លើសំណើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចខាងក្រោម៖

-អង្គការសង្គមស៊ីវិល បានលើកឡើងនូវសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន៩មាត្រា ដែលក្នុងនោះរួមមាន៖ **មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា២៤ មាត្រា២៥ មាត្រា៣១ មាត្រា៣២ និងមាត្រា៣៥**។ បន្ទាប់មក ក្រសួងមហាផ្ទៃក៏បានទទួលសំណើចំនួនពីរ ពីតំណាងអង្គការសង្គមស៊ីវិល ដែលស្នើសុំធ្វើវិសោធនកម្មបន្ថែមទៀតចំនួន៨មាត្រា គឺ៖ **១.**អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(**CCC**) និងអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(**NGO Forum**) និង**២.**សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១៨។ សំណើដែលសុំធ្វើវិសោធនកម្មមានចំនួនសរុប ១៧មាត្រា។

-លើមូលដ្ឋានខាងលើនេះ ក្រសួងមហាផ្ទៃបានគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីជ្រាប និងគោរពស្នើសុំគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់អំពីលទ្ធផលនៃអង្គវេទិកាលើកទី៣។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានអនុញ្ញាតជាគោលការណ៍ឱ្យក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ធ្វើការពិភាក្សាជាមួយតំណាងអង្គការសង្គមស៊ីវិល លើសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ឈរលើមូលដ្ឋានខាងលើ ក្រុមការងាររបស់រាជរដ្ឋាភិបាលបានធ្វើការប្រជុំពិគ្រោះយោបល់ជាមួយក្រុមតំណាងអង្គការសង្គមស៊ីវិល **បានចំនួន៣លើករួចហើយ** ដើម្បីស្វែងយល់បន្ថែមពីគោលបំណង មូលហេតុ និងខ្លឹមសារនៃការស្នើសុំធ្វើវិសោធនកម្ម ដោយបានពិនិត្យពិភាក្សាគ្នាបាន **ចំនួន៥មាត្រា** ដោយមានការចូលរួមសង្កេតការណ៍ពីតំណាងស្ថានទូតនានា និងភ្នាក់ងារដៃគូអភិវឌ្ឍន៍ ជាពិសេសតំណាងការិយាល័យឧត្តមស្នងការជាន់ខ្ពស់ សម្រាប់សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ(UN-OHCHR)។ កិច្ចដំណើរការនៃការពិភាក្សានេះ ហាក់មានភាពយឺតយ៉ាវ ដោយសារក្រុមតំណាងអង្គការសង្គមស៊ីវិលនៅពុំទាន់ស្រុះស្រួល និងឯកភាពគ្នាលើខ្លឹមសារ និងមូលហេតុនៃការធ្វើវិសោធនកម្មនៅឡើយ។

-ទោះបីជាយ៉ាងនេះក្ដី ក្រុមការងារអន្តរក្រសួងរបស់រាជរដ្ឋាភិបាល បានប្ដេជ្ញានឹងបន្តការពិភាក្សាអំពីសំណើសុំធ្វើវិសោធនកម្មច្បាប់ដែលនៅសេសសល់រហូតដល់បញ្ចប់ ដែលកិច្ចប្រជុំពិគ្រោះយោបល់លើកទី៤ គ្រោងនឹងរៀបចំឡើងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ខាងមុខនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល សូមជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ*